ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា

ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

លេខ ៦៣/ /១៤/សកប

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង

-------------

ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាទាំងអស់ដែលកំពុងស្នាក់នៅធ្វើការមិនស្របច្បាប់ក្នុងប្រទេសថៃ ដូចតទៅ៖

ក-សូមបងប្អូនពលករកម្ពុជាទាំងអស់ទៅចុះបញ្ជីនៅ "មជ្ឈមណ្ឌលច្រកចេញចូលតែមួយ" នៅតាមបណ្តាខេត្តថៃ ដែលខ្លួនកំពុងស្នាក់នៅ។

ខ-ចំពោះបងប្អូនពលករកម្ពុជាណាដែលមានលិខិតឆ្លងដែនរួចហើយ ក្រោយពីបានចុះបញ្ជីនៅ "មជ្ឈមណ្ឌលច្រកចេញចូលតែមួយ" ត្រូវបន្តដាក់ពាក្យសុំទិដ្ឋាការស្នាក់នៅ និង បណ្ណការងារអចិន្ត្រៃយ៍ នៅថៃ។

គ-ចំពោះបងប្អូនពលករកម្ពុជាណាដែលពុំមានលិខិតឆ្លងដែន ក្រោយពីបានចុះបញ្ជីនៅ "មជ្ឈមណ្ឌលច្រកចេញចូលតែមួយ" រួចហើយ ត្រូវសុំលិខិតឆ្លងដែនពីអាជ្ញាធរកម្ពុជា។ ក្រោយពីបានលិខិតឆ្លងដែនហើយ ត្រូវបន្តដាក់ពាក្យសុំទិដ្ឋាការស្នាក់នៅ និង បណ្ណការងារចិន្ត្រៃយ៍ នៅថៃ។

ឃ-ក្រសួងមហាផ្ទៃកម្ពុជានឹងរៀបចំធ្វើលិខិតឆ្លងដែននៅទីតាំងចំនួន៤ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺនៅ ប៉ោយប៉ែត ប៉ៃលិន ចាំយាម និង អូរស្មាច់។

ក្នុងករណីជនណាម្នាក់រារាំងបងប្អូនពលករមិនឲ្យទៅចុះឈ្មោះ ឬ មានចំងល់ផ្សេងៗ សូមប្រញាប់ទាក់ទងមកស្ថានឯកអគ្គរាជទូតកម្ពុជាតាមរយៈលេខទូរស័ព្ទដូចខាងក្រោម៖

-០៩៨៥០៥១៥៥០

-០៨២៧៩៩០០០៧

-០៨១៤៤១៩៨៧២

សូមអរគុណ។

បាងកក ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤

518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310
Tel. : (662) 957 5851, 957 5852 Fax : (662) 957 5850 E-mail : recbkk@cscoms.com